សេចក្តីសង្ខេប

# គោលការណ៍ណែនាំស្ម័គ្រចិត្ត សម្រាប់ធានានិរន្តរភាពនៃការនេសាទខ្នាតតូចក្នុងបរិបទនៃសន្តិសុខស្បៀង និងការលុបបំបាត់ភាពក្រីក្រ



បោះផ្សាយដោយ

**សហគមន៍អន្តរជាតិទ្រទ្រង់កម្មករនេសាទ**

**International Collective in Support of Fishworkers (ICSF)**

27 College Road Chennai 600
006, India

Phone: (91) 44–2827 5303
Fax: (91) 44–2825 4457
Email: icsf@icsf.net
Website: www.icsf.net

ICSF គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយដែលធ្វើការលើបញ្ហានានាដែលជាកង្វល់របស់កម្មករនេសាទលើពិភពលោក។ នេះជាឋានៈទទួលស្គាល់ដោយក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមនៃអ.ស.ប និងចែងក្នុងបញ្ជីពិសេសរបស់អង្គការពលកម្មអន្តរជាតិ (ILO) អំពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ។ អង្គការនេះក៏មានឋានៈជាសម្ព័ន្ធភាពជាមួយអង្គការ FAO ផងដែរ។

ក្នុងឋានៈជាបណ្តាញពិភពលោកនៃអង្គការសហគមន៍ គ្រូបង្រៀន អ្នកបច្ចេកទេស អ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រ សកម្មភាពរបស់ ICSF មានជាអាទិ៍ ការតាមដាន និងស្រាវជ្រាវ ការផ្លោះប្តូរ និងបណ្តុះបណ្តាល យុទ្ធនាការ និងសកម្មភាពនានា ក៏ដូចជា សហគមន៍ផងដែរ។

ជាមួយការគាំទ្រពី

**គម្រោងប្រព័ន្ធអេកូឡូស៊ីនៃឆកសមុទ្របេងហ្គាល (BOBLME)**

ភូកេត ប្រទេសថៃ

បង់ក្លាដែស ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ម៉ាល់ឌីវ មីយ៉ាន់ម៉ា ស្រីឡង្កា និងប្រទេសថៃ ដែលសហការគ្នាតាមរយៈ គម្រោងប្រព័ន្ធអេកូឡូស៊ីឆកសមុទ្រ បេងហ្គាល (BOBLME) ដើម្បីកែលម្អជីវិតរបស់ប្រជាជនតាមឆ្នេរសមុទ្រនៃប្រទេសទាំងនេះ តាមរយៈការកំណែលម្អការគ្រប់គ្រងថ្នាក់តំបន់នៃបរិស្ថាននៃឆកសមុទ្របេងហ្គាល និងការនេសាទនៅក្នុងឆកសមុទ្រនេះ។

**ឆ្នាំ ២០១៥**

បោះពុម្ពនៅ

**L.S. Graphic Prints**
#13, Swamy Naicken
Street, Chintadripet,
Chennai 600 002.

រចិត្រូប និងរចនាបថដោយ Arjun Shankar

ISBN 978 93 80802 46 6

សេចក្តីសង្ខេប

# គោលការណ៍ណែនាំស្ម័គ្រចិត្តសម្រាប់ធានានិរន្តរភាពនៃការនេសាទខ្នាតតូចក្នុងបរិបទនៃសន្តិសុខស្បៀង និងការលុបបំបាត់ភាពក្រីក្រ

គោលការណ៍ណែនាំស្ម័គ្រចិត្តសម្រាប់ធានានិរន្តរភាពការនេសាទខ្នាតតូច ក្នុងបរិបទនៃសន្តិសុខស្បៀងនិងការលុបបំបាត់ភាពក្រីក្រ(គោលការណ៍ណែនាំSSF) ត្រូវបានប្រទេសជាសមាជិកនៃអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ (FAO) អនុម័ត និងបានឯកភាពជាផ្លូវការ កាលពីខែមិថុនា ឆ្នាំ២០១៤ សម្រាប់ជាបរិធានអន្តរជាតិមួយ។

អ្វីដែលពិសេសនៅក្នុងគោលការណ៍ណែនាំ SSF នេះគឺថា វាត្រូវបានរៀបចំឡើងជាលទ្ធផលមួយក្នុងដំណើរការយ៉ាងវែងមួយនៃការប្រឹងប្រែងរបស់កម្មករនេសាទខ្នាតតូចនៅជុំវិញពិភពលោក ដែលអំពាវនាវឲ្យមានការទទួលស្គាល់កាន់តែច្រើនឡើង នូវឋានានុក្រមនិងតួនាទីរបស់ពួកគេនៅក្នុងវិស័យនេសាទនៃប្រទេសរបស់ពួកគេ។

ទោះបីអ្នកនេសាទខ្នាតតូចទូទាំងពិភពលោក គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចមច្ឆជាតិក៏ដោយ អ្នកនេសាទទាំងនោះត្រូវបានគេមើលរម្លង និងច្រើនតែត្រូវបានរើសអើង នៅក្នុងដំណើរការទំនើបកម្មនៃវិស័យនេសាទ។ ទោះបីមានការមិនអើពើបែបនេះក៏ដោយ វិស័យនេះនៅតែមានអត្ថិភាព និងនៅតែរស់រវើកនៅក្នុងប្រទេសជាច្រើន។

ដោយសារតែរយៈពេលជាច្រើនទសវត្សរ៏នៃ"ការមិនអើពើជាផ្លូវការ"បែបនេះក្នុងប្រទេសជាច្រើន និងទោះបីសហគមន៍អ្នកនេសាទខ្នាតតូចបានរួមចំណែកជាផលចាប់យ៉ាងច្រើនក៏ដោយ អ្នកទាំងនេះនៅតែបន្តរស់ក្នុងភាពក្រីក្រ និងគ្មានការយកចិត្តទុកដាក់ និងបាត់បង់សិទ្ធិមនុស្សរបស់ខ្លួន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងវប្បធម៌។

គោលការណ៍ណែនាំ SSF គឺជាការទទួលស្គាល់មួយអំពីតថភាពនេះ ដោយប្រទេសជាសមាជិក FAO ទន្ទឹមនឹងនេះ វាក៏ជាកិច្ចប្រឹងប្រែងមួយដើម្បីធ្វើឲ្យការនេសាទខ្នាតតូច ក្លាយជាចំណុចស្នូលនៃការអភិវឌ្ឍ និងគ្រប់គ្រងការនេសាទផងដែរ។

សមាគមន៍អន្តរជាតិទ្រទ្រង់កម្មករនេសាទ(ICSF) ធ្លាប់ជាអង្គការសង្គមស៊ីវិល(CSO)ឈានមុខមួយ ដែលដើរតួយ៉ាងសកម្មក្នុងការរៀបចំគោលការណ៍ណែនាំទាំងនេះ នៅក្នុងដំណើរការតាមបែបផែននៃការចូលរួមទូលំទូលាយបំផុតមួយ។ តាមពិត គោលការណ៍ណែនាំនេះត្រូវបានឧទ្ទិសជាផ្លូវការដោយ FAO/UN ជាអនុស្សាវរីយ៍របស់ Chandrika Sharma លេខាធិការប្រតិបត្តិនៃ ICSF ដែលជាអ្នកឈានមុខខាងសិទ្ធិរបស់កម្មករនេសាទខ្នាតតូចនៅជុំវិញពិភពលោក។ គាត់បានបាត់ខ្លួនចាប់តាំងពីពេលបាត់យន្តហោះម៉ាឡេស៊ី ជើងហោះហើរ MH ៣៧០ កាលពីខែមីនា ឆ្នាំ២០១៤។ គាត់បានធ្វើដំណើរទៅម៉ុងហ្គោលីដើម្បីចូលរួមក្នុងសន្និសីទមួយរបស់អង្គការ FAO ដើម្បីបង្កើតការគាំទ្រដល់ការអនុម័តលើគោលការណ៍ណែនាំនេះ។

គោលការណ៍ណែនាំនេះមានច្រើនជាង ១០០វាក្យខ័ណ្ឌ ដែលចែកចេញជា ១៣ផ្នែក។ ឯកសារនេះគ្រាន់តែជាសេចក្តីសង្ខេបមួយនៃខ្លឹមសារក្នុងសេចក្តីណែនាំនោះប៉ុណ្ណោះ។ ឯកសារនេះ ត្រូវបានផលិតសម្រាប់ ICSF ដោយ John Kurien សមាជិកស្ថាបនិកនៃ ICSF ដែលបានធ្វើការយ៉ាងហោចណាស់រយៈពេលបួនទសវត្សរ៍ជាមួយសហគមន៍អ្នកនេសាទខ្នាតតូចក្នុងតំបន់ជាច្រើនលើពិភពលោក ជាពិសេស នៅកេរ៉ាឡា ប្រទេសឥណ្ឌា។

# អារម្ភកថា

គោលការណ៍ណែនាំ SSF ត្រូវបានរៀបចំឡើងជាការបំពេញបន្ថែមលើក្រមរបស់ FAO ឆ្នាំ ១៩៩៥ ស្ដីពីការនេសាទប្រកបដោយការទទួលខុសត្រូវ។ គោលការណ៍ណែនាំនេះចែងអំពីការនេសាទខ្នាតតូច និងគ្របដណ្ដប់រាល់សកម្មភាពនានានៅក្នុងខ្សែចង្វាក់តម្លៃទាំងមូល ដែលធ្វើឡើងដោយបុរស និងស្ត្រី។ ការនេសាទខ្នាតតូច រួមចំណែកចំនួនពាក់កណ្ដាលនៃផលត្រីដែលចាប់បានលើពិភពលោក និងផ្ដល់ការងារដល់ ៩០ភាគរយនៃអ្នកនេសាទ និងកម្មករនេសាទលើពិភពលោក។ ការនេសាទ និងសហគមន៍នេសាទខ្នាតតូច តំណាងឲ្យអនុវិស័យសំបូរបែប និងឋាមវន្តមួយ ដែលពឹងផ្អែកជាពិសេសលើទីតាំងរបស់ខ្លួន។ ជាញឹកញាប់ ពួកគេគឺជាសហគ្រាសគ្រួសារ ដែលធ្វើការនៅក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន។ ពួកគេនៅតែមិនបានទទួលការយកចិត្តទុកដាក់ឡើយ។ ភាពក្រីក្រក្នុងសហគមន៍នេសាទខ្នាតតូច មានសណ្ឋានខុសៗគ្នាជាច្រើន។ ការបន្តរក្សា និងបង្កើនភាគចំណែកនៃវិស័យនេសាទខ្នាតតូច បានប្រឈមការលំបាក និងឧបសគ្គជាច្រើន។ គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើង តាមរយៈដំណើរការពិគ្រោះយោបល់តាមបែបផែននៃការចូលរួមដោយឡែកមួយបែប។ គោលការណ៍ណែនាំនេះមានសង្គតិភាពជាមួយស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ និងលើកកំពស់ស្តង់ដារទាំងនេះ។



## ១. គោលបំណង

គោលការណ៍ណែនាំ SSF មានគោលបំណងធានាថា ការនេសាទខ្នាតតូចនឹងៈ

- ពង្រីកសន្តិសុខស្បៀងលើពិភពលោក
- លើកកំពស់វិភាគទានរបស់ខ្លួនចំពោះអនាគតនៃសេដ្ឋកិច្ច និងសង្គមនៃផែនដីយើងនេះ
- រួមចំណែកកែលម្អស្ថានភាពសេដ្ឋកិច្ចសង្គមរបស់កម្មករនេសាទ និង
- ធានាការប្រើប្រាស់ធនធានជលផលដោយនិរន្តរភាព។

នៅក្នុងដំណើរការនេះ គោលការណ៍ណែនាំនេះគួរតែបង្កើនការយល់ដឹងជាសាធារណៈអំពីតួនាទី វិភាគទាន និងសក្តានុពលនៃវិស័យនេសាទខ្នាតតូច។

គោលបំណងទាំងនេះគួរតែអាចសម្រេចបាន តាមរយៈការលើកកំពស់អភិក្រមសិទ្ធិមនុស្ស។ សហគមន៍អ្នកនេសាទខ្នាតតូច គួរតែបានពង្រឹងភាពអង់អាច ដើម្បីចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងចាប់យកការទទួលខុសត្រូវលើការប្រើប្រាស់ធនធានជលផលដោយនិរន្តរភាព។ នៅក្នុងគោលការណ៍ណែនាំនេះ មានការសង្កត់ធ្ងន់លើតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និងកង្វល់នានា ព្រមទាំងផលប្រយោជន៍របស់ក្រុមជនងាយរងគ្រោះ និងដែលពុំបានទទួលការយកចិត្តទុកដាក់ ក្នុងចំណោមសហគមន៍នេសាទខ្នាតតូច។



## ២. ចរិកលក្ខណៈ និងវិសាលភាព

គោលការណ៍ណែនាំ SSF មានលក្ខណៈជាគោលការណ៍ស្ម័គ្រចិត្ត និងសម្រាប់អនុវត្តនៅទូទាំងពិភពលោក ដោយផ្តោតលើប្រទេសកំពុងអភិវឌ្ឍន៍។ ឯកសារនេះចែងគ្របដណ្តប់សកម្មភាពដែលទាក់ទងនឹងការនេសាទទាំងអស់ ទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប។ ឯកសារនេះចែងសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ដែលទាក់ទងនឹងការនេសាទ ដែលរួមទាំង ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងវិស័យឯកជន។ គោលការណ៍ណែនាំនេះទទួលស្គាល់ពីភាពខុសៗគ្នានៃការនេសាទខ្នាតតូច និងទទួលស្គាល់ថា ពុំមាននិយមន័យស្តង់ដារណាមួយសម្រាប់ការនេសាទនេះឡើយ។ តាមរយៈដំណើរការនៃការចូលរួម និងមានតម្លាភាព រដ្ឋនានាគួរឲ្យនិយមន័យអំពីថាតើការនេសាទបែបណាដែលចាត់ទុកថាខ្នាតតូច ដូច្នេះវាស្ថិតនៅក្នុងក្របខ័ណ្ឌនៃគោលការណ៍ណែនាំទាំងនេះ និងគួរកំណត់អត្តសញ្ញាណប្រពលរដ្ឋដែលងាយរងគ្រោះបំផុតនៅក្នុងវិស័យនេសាទខ្នាតតូចទាំងនោះ ដោយហេតុថា គោលការណ៍ណែនាំនេះ មានការពាក់ព័ន្ធបំផុតសម្រាប់ពួកគេ។ គោលការណ៍ណែនាំនេះគួរតែបានបកស្រាយ និងយកទៅអនុវត្ត ស្របជាមួយប្រព័ន្ធច្បាប់ និងស្ថាប័នជាតិ។



## ៣. គោលការណ៍នាំមុខ

គោលការណ៍ណែនាំទាំងនេះ បានផ្អែកលើគោលការណ៍នាំមុខចំនួន ១៣។ គោលការណ៍ទាំងនេះបានផ្អែកលើស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ស្តង់ដារនៃការនេសាទដោយការទទួលខុសត្រូវ និងទម្លាប់អនុវត្តនៃការអភិវឌ្ឍដោយចីរភាព ដែលផ្តោតការយកចិត្តទុកដាក់លើក្រុមជនងាយរងគ្រោះ និងដែលមិនបានទទួលការយកចិត្តទុកដាក់ និងតម្រូវការដើម្បីគាំទ្រដល់ការផ្តល់សមិទ្ធកម្មជាបន្តបន្ទាប់នៃសិទ្ធិទទួលបានស្បៀងអាហារគ្រប់គ្រាន់។

គោលការណ៍ទាំងនោះមានជាអាទិ៍៖

០១. សិទ្ធិមនុស្ស និងភាពថ្លៃថ្នូររបស់មនុស្ស
០២. ការគោរពចំពោះវប្បធម៌
០៣. ភាពគ្មានការរើសអើង
០៤. សមភាព និងសមធម៌យេនឌ័រ
០៥. សមធម៌ និងសមភាព
០៦. ការពិគ្រោះយោបល់ និងការចូលរួម
០៧. នីតិរដ្ឋ
០៨. តម្លាភាព
០៩. គណនេយ្យភាព
១០. និរន្តរភាពសេដ្ឋកិច្ច សង្គម និងបរិស្ថាន
១១. អភិក្រមគ្រប់ជ្រុងជ្រោយ និងចម្រុះ
១២. ការទទួលខុសត្រូវសង្គម និង
១៣. លទ្ធភាពធ្វើបាន និងភាពស្ថិតស្ថេរខាងសង្គម និងសេដ្ឋកិច្ច

## ៤. ទំនាក់ទំនងជាមួយបរិធានអន្តរជាតិដទៃទៀត

គោលការណ៍ណែនាំ SSF គួរតែបានបកស្រាយ និងយកទៅអនុវត្តឲ្យមានសង្គតិភាពជាមួយសិទ្ធិ និងកាតព្វកិច្ចនានាដែលមានស្រាប់ នៅក្រោមច្បាប់ជាតិ និងអន្តរជាតិ និងដោយមានការគិតគូរអំពីការប្តេជ្ញាចិត្តនៅក្រោមបរិធាននានាដែលនៅជាធរមាន ទាំងនៅថ្នាក់តំបន់ និងអន្តរជាតិ។

គោលការណ៍ណែនាំទាំងនេះអាចយកមកប្រើប្រាស់ដើម្បីណែនាំដល់វិសោធនកម្ម និងលើកទឹកចិត្តឲ្យមានបញ្ញត្តិថ្មីៗ ឬ បន្ថែមទៀត នៅក្នុងលិខិតបទដ្ឋានគតិយុត្តិ និងបទបញ្ជានានា។ ទោះជាយ៉ាងណាក៏ដោយ គ្មានអ្វីនៅក្នុងគោលការណ៍ណែនាំនេះ ដែលគួរតែចាត់ទុកថាជាការកំហិត ឬ ការធ្វើឲ្យបាត់បង់សិទ្ធិ ឬ កាតព្វកិច្ចណាមួយ របស់រដ្ឋនៅក្រោមច្បាប់អន្តរជាតិណាមួយនោះឡើយ។



## ៥. អភិបាលកិច្ចលើសិទ្ធិកាន់កាប់ក្នុងការនេសាទខ្នាតតូច និងការគ្រប់គ្រងធនធាន

### ក. អភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ

អភិបាលកិច្ចលើសិទ្ធិកាន់កាប់ធនធានសមស្របប្រកបដោយការទទួលខុសត្រូវ មានសារៈសំខាន់ជាស្នូលចំពោះការសម្រេចបានសមិទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងវប្បធម៌ និងការសម្រេចបានលទ្ធផលខាងសិទ្ធិមនុស្សរបស់សហគមន៍នេសាទខ្នាតតូច។ សហគមន៍នេសាទខ្នាតតូចគួរតែទទួលបាននូវការធានាការពារសិទ្ធិកាន់កាប់សមស្របដោយសមធម៌និងសមស្របទៅតាមលក្ខខណ្ឌសង្គម-វប្បធម៌ លើធនធានជលផល កន្លែងនេសាទ និងដីធ្លី និងព្រៃឈើដែលនៅជិតខាង។ ការយកចិត្តទុកដាក់ជាពិសេស គួរតែបានផ្តល់ចំពោះសិទ្ធិកាន់កាប់របស់ស្ត្រី។ គ្រប់ទម្រង់នៃសិទ្ធិកាន់កាប់ស្របច្បាប់ គួរតែមានថែង កត់ត្រា និងគោរព។ កិច្ចការនេះគួរតែបានធ្វើឡើង ជាមួយលិខិតបទដ្ឋានគតិយុត្តិ ប្រសិនបើចាំបាច់ ដោយគិតគូរជាពិសេសនូវសិទ្ធិជាប្រពៃណី និងការនិយមចូលចិត្តចំពោះធនធានវារីជាតិ និងដីធ្លីរបស់ជនជាតិដើមនិងជនជាតិភាគតិច។ ក្នុងករណីដែលកំណែទម្រង់ច្បាប់ផ្តល់សិទ្ធិដល់ស្ត្រី កំណែទម្រង់ទាំងនោះគួរតែមានភាពគ្នាជាមួយប្រព័ន្ធកាន់កាប់ជាប្រពៃណី។ តួនាទីរបស់សហគមន៍នេសាទខ្នាតតូច និងជនជាតិដើម ដើម្បីស្តារ អភិរក្ស ការពារ និងសហគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីដែនទឹក និងតំបន់ឆ្នេរនៅតាមមូលដ្ឋាន គួរតែបានទទួលស្គាល់។ ក្នុងករណីដែលរដ្ឋជាកម្មសិទ្ធិករ ឬ ត្រួតត្រាលើដីធ្លី និងធនធានទឹក សិទ្ធិកាន់កាប់របស់រដ្ឋ គួរតែមានថែងដោយគិតគូរផងដែរនូវគោលបំណងខាងសេដ្ឋកិច្ចសង្គម និងបរិស្ថាន ជាពិសេស នៅពេលដែលប្រព័ន្ធអេកូឡូស៊ីទាំងនេះស្ថិតក្រោមការប្រើប្រាស់ និងគ្រប់គ្រងរួមគ្នាដោយសហគមន៍នេសាទខ្នាតតូច។

ការផ្តល់ជម្រើសសម្រាប់ការនេសាទខ្នាតតូចនៅក្នុងដែនទឹកលើផ្ទៃប្រទេស ត្រូវបានដាក់បញ្ចូលទៅក្នុងក្រមប្រតិបត្តិសម្រាប់ការនេសាទប្រកបដោយការទទួលខុសត្រូវ (មាត្រា ៦.១៨)។ ផ្អែកលើប្រការនេះ រដ្ឋគួរអនុវត្តវិធានការនានា ដូចជា កំណត់តំបន់ដាច់ដោយឡែកសម្រាប់ការនេសាទខ្នាតតូច។ មុនពេលដែលចុះកិច្ចព្រមព្រៀងលើការប្រើប្រាស់ធនធានជាមួយភាគីទីបី គួរមានការពិចារណាលើការទាមទាររបស់សហគមន៍នេសាទខ្នាតតូចលើកន្លែងបែបនេះ។

អ្នកប្រើប្រាស់ផ្សេងទៀត កំពុងបង្កើនភាពប្រកួតប្រជែងក្នុងកន្លែងនេសាទខ្នាតតូច ដែលនាំឲ្យមានជម្លោះ។ រដ្ឋគួរធានាថា សហគមន៍នេសាទខ្នាតតូច បានទទួលការគាំទ្រជាពិសេស និងមិនត្រូវសម្រេចធ្វើការជន្លៀសដោយបំពាន ឬ រំលោភ ឬបំបិទសិទ្ធិស្របច្បាប់របស់ពួកគេឡើយ។ ក្នុងករណីដែលមានគម្រោងអភិវឌ្ឍន៍ខ្នាតធំ រដ្ឋ និងភាគីដទៃទៀត គួរធ្វើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងធ្វើការសិក្សាផលប៉ះពាល់ដែលពាក់ព័ន្ធ ដើម្បីប៉ាន់ប្រមាណផលប៉ះ ពាល់លើសហគមន៍នេសាទខ្នាតតូច។

រដ្ឋគួរដោះស្រាយឲ្យបានទាន់ពេលវេលា និងតាមវិធីដែលចំណាយទាប និងមានប្រសិទ្ធភាពនូវជម្លោះលើសិទ្ធិកាន់កាប់ ដែលពាក់ព័ន្ធនឹងសហគមន៍នេសាទខ្នាតតូច ដោយផ្តល់សំណងការខូចខាតដែលអាចរាប់បញ្ចូល បដិទាន ប្រាក់សំណង ការប៉ះប៉ូវឲ្យបានសមរម្យ និងការជួសជុលឡើងវិញ ដែលអាចធ្វើបានភ្លាមៗ។

ការផ្លាស់ប្តូរទីកន្លែងដោយសារតែគ្រោះមហន្តរាយធម្មជាតិ និង/ឬ ជម្លោះប្រដាប់អាវុធកំពុងតែកើនឡើង ដែលប៉ះពាល់ដល់សហគមន៍នេសាទខ្នាតតូច។ រដ្ឋគួរប្រឹងប្រែងឲ្យអស់លទ្ធភាព ដើម្បីស្តារលទ្ធភាពនៃការធ្វើនេសាទនៅកន្លែងនេសាទជាប្រពៃណី និងដីក្នុងតំបន់ឆ្នេរ ដោយគិតគូរអំពីនិរន្តរភាពនៃធនធានជលផលផងដែរ។ ក្នុងកាលៈទេសៈទាំងនេះ យន្តការនានាគួរតែបានបង្កើតឡើងដើម្បីគាំទ្រដល់សហគមន៍ដែលរងគ្រោះដោយសារអំពើហិង្សាធ្ងន់ធ្ងរចំពោះសិទ្ធិមនុស្សដើម្បីកសាងជីវភាពឡើងវិញ ហើយរាល់ការរើសអើងចំពោះស្ត្រីនៅក្នុងសិទ្ធិកាន់កាប់ គួរតែបានលុបបំបាត់។

### ខ. ការគ្រប់គ្រងធនធានដោយនិរន្តរភាព

គួរមានការអនុម័តវិធានការសម្រាប់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពសម្រាប់រយៈពេលវែងនូវធនធានជលផល និងមានការទទួលស្គាល់អំពីតម្រូវការនិងឱកាសធ្វើនេសាទខ្នាតតូច។ សិទ្ធិ ត្រូវតែដើរទន្ទឹមគ្នាជាមួយការទទួលខុសត្រូវ។ សិទ្ធិកាន់កាប់ ត្រូវមានតុល្យភាព ជាមួយករណីយកិច្ច ដែលផ្តោតលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាព។

ការនេសាទខ្នាតតូច គួរអនុវត្តតាមទម្លាប់នៃការនេសាទដែលបង្កមហន្តរាយតិចតួចបំផុតចំពោះបរិស្ថាន និងប្រភេទសត្វនានាដែលពាក់ព័ន្ធ។ រដ្ឋ គួរគាំទ្រដល់ការនេសាទខ្នាតតូច ដើម្បីអាចមានការរ៉ាប់រងការទទួលខុសត្រូវលើការគ្រប់គ្រងធនធាន។ រដ្ឋគួរជម្រុញសហគមន៍ឲ្យចូលរួម នៅក្នុងការរៀបចំទម្រង់ប្លង់ ផែនការ និងការអនុវត្តវិធានការគ្រប់គ្រង ដោយធានាឲ្យស្ត្រីនិងក្រុមពលរដ្ឋងាយរងគ្រោះដទៃទៀត បានចូលរួមដោយសមធម៌។ នៅក្នុងវិសាលភាពនៃច្បាប់ជាតិ រដ្ឋគួរលើកកំពស់ប្រព័ន្ធនៃការគ្រប់គ្រងតាមបែបចូលរួម។

រដ្ឋគួរបង្កើត និងលើកកំពស់ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល(MCS) ដែលអាចអនុវត្តបាន និងសមស្របសម្រាប់ការនេសាទខ្នាតតូច។ រដ្ឋគួរមានគោលដៅរារាំង ទប់ស្កាត់ និងលុបបំបាត់រាល់ទម្លាប់នៃការនេសាទល្មើសច្បាប់ និងបែបបំផ្លាញ ហើយអ្នកនេសាទខ្នាតតូច គួរគាំទ្រដល់ប្រព័ន្ធ MCS និងផ្តល់ផងដែរឲ្យអាជ្ញាធរនូវព័ត៌មានដែលចាំបាច់សម្រាប់ការគ្រប់គ្រង។

រដ្ឋគួរគូសបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់ភាគីទាំងអស់ ដែលទាក់ទងនឹងការចាត់ចែងសហគ្រប់គ្រង និងពឹងផ្អែកលើដំណើរការដែលគាំទ្រដោយច្បាប់។ ការនេសាទខ្នាតតូច គួរមាន

អ្នកតំណាងនៅក្នុងសមាគម និងស្ថាប័នវិជ្ជាជីវៈដែលពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ និងចូលរួមយ៉ាងសកម្មនៅក្នុងដំណើការធ្វើសេចក្តីសម្រេច និងរៀបចំគោលនយោបាយដែលទាក់ទងនឹងការនេសាទ។

នៅក្នុងការគាំទ្រដល់សហគ្រប់គ្រង ទាំងរដ្ឋ និងអ្នកនេសាទខ្នាតតូច គួរគាំទ្រឲ្យបុរស និងស្ត្រីចូលរួមនៅក្នុងការប្រមូលផល និងនៅក្នុងប្រតិបត្តិការនៅមុន និងក្រោយការប្រមូលផលផងដែរ ដើម្បីរួមវិភាគទានជាចំណេះដឹង ទស្សនៈវិស័យ និងតម្រូវការរបស់ពួកគេ។

រដ្ឋគួរតែធានាថា សិទ្ធិកាន់កាប់របស់សហគមន៍នេសាទខ្នាតតូច ត្រូវបានការពារ ក្នុងករណីដែលបញ្ហាឆ្លងដែនជាប់ពាក់ព័ន្ធជាមួយដែនទឹក និងធនធានរួម។

រដ្ឋគួរជៀសវាងគោលនយោបាយ និងវិធានការហិរញ្ញវត្ថុ ដែលរួមចំណែកក្នុងការបង្កើតសមត្ថភាពនេសាទហួសកម្រិត ដែលនាំទៅរកការនេសាទហួសកម្រិត និងបង្កផលប៉ះពាល់អវិជ្ជមានមកលើការនេសាទខ្នាតតូច។



## ៦. ការអភិវឌ្ឍសង្គម មុខរបរ និងការងារសមរម្យ

ភាគីទាំងអស់គួរប្រកាន់យកអភិក្រមគ្រប់ជ្រុងជ្រោយនៅក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងការនេសាទខ្នាតតូច។ រដ្ឋគួរលើកកំពស់ការវិនិយោគលើវិស័យសុខាភិបាល ការអប់រំ ការអាននិងសរសេរ ការដាក់បញ្ចូលប្រព័ន្ធឌីជីតាល់ និងជំនាញបច្ចេកទេសដទៃទៀត។

រដ្ឋគួរលើកកំពស់បណ្តាញសន្តិសុខសង្គមសម្រាប់ពលករទាំងអស់ ក្នុងការនេសាទខ្នាតតូច នៅក្នុងខ្សែចង្វាក់តម្លៃទាំងមូល។ រដ្ឋគួរគាំទ្រដល់ការបង្កើតប្រព័ន្ធសម្រាប់ការសន្សំប្រាក់ ឥណទាន និងការធានារ៉ាប់រង ដោយសង្កត់ធ្ងន់លើការរួមបញ្ចូលស្ត្រី និងការទទួលបានសេវាទាំងនេះពីសំណាក់ស្ត្រី។

ទាំងអស់គ្នាគួរទទួលស្គាល់សកម្មភាពទាំងអស់នៅក្នុងខ្សែចង្វាក់តម្លៃនៃការនេសាទខ្នាតតូចទាំងមូល ថាជាប្រតិបត្តិការសេដ្ឋកិច្ច និងវិជ្ជាជីវៈ។

រដ្ឋគួរលើកកំពស់ការងារសមរម្យសម្រាប់ទាំងអស់គ្នា។

រដ្ឋគួរធានាឲ្យមានការអនុវត្តដោយបើកចំហនូវសិទ្ធិរបស់អ្នកនេសាទខ្នាតតូច និងកម្មករនេសាទក្នុងការមានជីវភាពរស់នៅតាមស្តង់ដារសមរម្យ។ រដ្ឋគួរជម្រុញគោលនយោបាយសេដ្ឋកិច្ចជាបរិយាបន្ន គ្មានការរើសអើងនិងពេញលេញ ដើម្បីឲ្យពលករទាំងនេះអាចរកប្រាក់ចំណូលបានសមរម្យពីការងារ ដើមទុន និងការគ្រប់គ្រងរបស់ពួកគេ។ រដ្ឋ និងភាគីដទៃទៀត គួរគាំទ្រឲ្យមានឱកាសរកប្រាក់ចំណូលពីប្រភពផ្សេង។ គួរបង្កើតលក្ខខណ្ឌនានាសម្រាប់សហគមន៍នេសាទខ្នាតតូច ដើម្បីអនុវត្តសកម្មភាពដែលទាក់ទងនឹងការនេសាទរបស់ពួកគេ។

ចំណាកស្រុកគឺជាយុទ្ធសាស្ត្រទូទៅមួយនៃរបរចិញ្ចឹមជីវិត។ រដ្ឋគួរទទួលស្គាល់ និងដោះស្រាយមូលហេតុជាឫសគល់ និងផលវិបាកនៃចលនាឆ្លងដែនរបស់អ្នកនេសាទ។

រដ្ឋគួរដោះស្រាយបញ្ហាសុខភាពក្នុងមុខរបរ សុវត្ថិភាព និងលក្ខខណ្ឌការងារមិនត្រឹមត្រូវ។ រដ្ឋគួរធ្វើការឆ្ពោះទៅរកការលុបបំបាត់ពលកម្មដោយបង្ខំ និងទប់ស្កាត់ទាសភាពដោយសារជាប់បំណុល។

រដ្ឋគួរផ្តល់លទ្ធភាពក្នុងការចូលរៀន និងសេវាអប់រំ ដោយទទួលស្គាល់ពីសារៈសំខាន់នៃសុខុមាលភាពកុមារ និងការអប់រំសម្រាប់អនាគតរបស់ពួកគេ។

ភាពស្មុគស្មាញនៃសុវត្ថិភាពនៅលើផ្ទៃសមុទ្រនិងក្នុងដែនទឹកសាប និងមូលហេតុជាច្រើននៃភាពទន់ខ្សោយ គួរតែបានទទួលស្គាល់ពីគ្រប់ភាគីទាំងអស់។

សុវត្ថិភាព និងសុខភាពក្នុងមុខរបរ នៅក្នុងការនេសាទខ្នាតតូច ត្រូវតែបានដាក់បញ្ចូលទៅក្នុងការគ្រប់គ្រងវិស័យជលផលជារួម។

រដ្ឋគួរការពារសិទ្ធិមនុស្ស និងភាពថ្លៃថ្នូររបស់អ្នកពាក់ព័ន្ធក្នុងការនេសាទខ្នាតតូច នៅក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធ។

## ៧. ខ្សែចង្វាក់តម្លៃ សកម្មភាពកែច្នៃ និងពាណិជ្ជកម្ម

តួនាទីស្នូលនៃអនុវិស័យកែច្នៃនៅក្នុងការនេសាទខ្នាតតូច គួរតែបានការទទួលស្គាល់ពីភាគីទាំងអស់។ ស្ត្រីដើរតួស្នូលនៅក្នុងការកែច្នៃ ហើយភាគីទាំងអស់គួរតែទទួលស្គាល់ប្រការនេះ។

រដ្ឋគួរពង្រឹង និងផ្តល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសមស្រប រចនាសម្ព័ន្ធចាត់ចែង និងការអភិវឌ្ឍសមត្ថភាពសម្រាប់ការកែច្នៃ។

ត្រូវមានការទទួលស្គាល់ទម្រង់ជាប្រពៃណីនៃសមាគមអ្នកនេសាទ និងកម្មករនេសាទ។

ត្រូវស្វែងរកវិធីនានាដើម្បីបញ្ចៀសការបាត់បង់នៅក្នុងពេលកែច្នៃ និងបង្កើតតម្លៃបន្ថែម។

រដ្ឋគួរលើកកំពស់ពាណិជ្ជកម្មផលនេសាទខ្នាតតូច ដោយសមធម៌ និងគ្មានការរើសអើង នៅក្នុងទីផ្សារនៅតាមមូលដ្ឋាន ថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ ការជម្រុញពាណិជ្ជកម្មផលនេសាទជាអន្តរជាតិ មិនគួរបង្កផលអវិជ្ជមានមកលើតម្រូវការអាហារូបត្ថម្ភរបស់ប្រជាពលរដ្ឋឡើយ ព្រោះថា សម្រាប់អ្នកទាំងនេះ ស្បៀងអាហារដែលមានថ្លៃទាប មានតួនាទីសំខាន់បំផុតក្នុងរបបអាហារ និងសុខុមាលភាពអាហារូបត្ថម្ភជារួម។

អត្ថប្រយោជន៍ពីពាណិជ្ជកម្មអន្តរជាតិ គួរតែបានបែងចែកសមស្រប ហើយគួរមានការដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងការនេសាទដែលមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការធ្វើអាជីវកម្មធនធានជលផលលើសកម្រិត ដើម្បីបំពេញតម្រូវការលើទីផ្សារ។

ការវាយតម្លៃបរិស្ថាន សង្គមនិងការវាយតម្លៃផ្សេងទៀតដែលពាក់ព័ន្ធ (ក្នុងចំណោមការវាយតម្លៃដទៃទៀត) គួរតែជាផ្នែករួមមួយនៅក្នុងគោលនយោបាយ និងនីតិវិធីនានា ដែលបានអនុវត្ត ដើម្បីធានាថា ផលប៉ះពាល់អវិជ្ជមាននៃពាណិជ្ជកម្មអន្តរជាតិមកលើបរិស្ថាន និងវប្បធម៌ សន្តិសុខស្បៀង និងការចិញ្ចឹមជីវិតរបស់អ្នកនេសាទខ្នាតតូច អាចវាស់បាន និងដោះស្រាយដោយសមធម៌។

រដ្ឋគួរជម្រុញឲ្យមានការទទួលបានព័ត៌មានទាន់ពេលវេលា និងដោយសុក្រិត អំពីទីផ្សារ និងពាណិជ្ជកម្មសម្រាប់អ្នកពាក់ព័ន្ធនានានៅក្នុងខ្សែចង្វាក់តម្លៃនៃការនេសាទខ្នាតតូច។

## ៨. សមភាពយេនឌ័រ

ការបញ្ជ្រាបយេនឌ័រ គួរតែជាផ្នែករួមមួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ការនេសាទខ្នាតតូច។ រដ្ឋគួរគោរពតាមកាតព្វកិច្ចរបស់ខ្លួនដែលទាក់ទងនឹងកិច្ចការស្ត្រី ដូចមានចែងក្នុងច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងអនុវត្តបរិធាននានាដែលខ្លួនគឺជាភាគីសមាជិក។

គួរអនុម័តវិធានការជាក់លាក់ ដើម្បីដោះស្រាយការរើសអើងចំពោះស្ត្រី។ សមភាពយេនឌ័រ គួរតែបានធានា ដោយបង្កើតគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិ និងការកែប្រែគោលនយោបាយនានាដែលមិនស្របគ្នាជាមួយគោលបំណងនេះ។

គួររៀបចំប្រព័ន្ធវាយតម្លៃមុខងារ ដើម្បីប៉ាន់ប្រមាណផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិ គោលនយោបាយ និងសកម្មភាពនានា សម្រាប់កែលម្អឋានានុក្រមរបស់ស្ត្រី និងការសម្រេចបានសមភាពយេនឌ័រ។

គួរអភិវឌ្ឍន៍បច្ចេកវិទ្យាប្រសើរជាងមុន ដែលសំខាន់ និងសមស្របជាមួយការងាររបស់ស្ត្រី។



## ៩. ហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ការប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ ទាមទារឲ្យមានសកម្មភាពបន្ទាន់ និងប្រកបដោយមហិច្ឆិតា។ គួរផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះសហគមន៍នេសាទខ្នាតតូច ដែលរស់នៅតាមកោះតូចៗ។ គេចាំបាច់ត្រូវមានអភិក្រមចម្រុះ និងគ្រប់ជ្រុងជ្រោយ ជាមួយកិច្ចសហការអន្តរវិស័យ។ គួរមានផងដែរនូវផែនការនានាសម្រាប់ការបន្សាំ ការកាត់បន្ថយ និងការផ្តល់ជំនួយទៅតាមករណីសមស្រប។

នៅក្នុងករណីនៃគ្រោះមហន្តរាយ ដែលបង្កដោយមនុស្ស និងដែលបង្កការប៉ះពាល់មកលើការនេសាទខ្នាតតូច ភាគីដែលពាក់ព័ន្ធក្នុងបញ្ហានេះត្រូវរ៉ាប់រងការទទួលខុសត្រូវ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនានាមកលើទិដ្ឋភាពនានានៃសកម្មភាពកែច្នៃ និងពាណិជ្ជកម្ម គួរតែត្រូវបានយកមកពិចារណា។ គោលគំនិតអំពី‟ការកសាងឡើងវិញឲ្យបានល្អជាងមុន″ គួរតែបានយកមកអនុវត្ត នៅក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយ និងការស្តារឡើងវិញ។ ប្រសិទ្ធភាពថាមពល នៅតាមខ្សែចង្វាក់តម្លៃទាំងមូល ក៏ត្រូវតែបានលើកទឹកចិត្ត និងជម្រុញផងដែរ។



## ១០. សង្គតិភាពនៃគោលនយោបាយ ការសម្របសម្រួលស្ថាប័ន និងកិច្ចសហការ

ដើម្បីលើកកំពស់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយនៅក្នុងសហគមន៍នេសាទខ្នាតតូច រដ្ឋគួរទទួលស្គាល់តម្រូវការឲ្យមានគោលនយោបាយដែលមានសង្គតិភាព និងធ្វើការឆ្ពោះទៅបង្កើតគោលនយោបាយបែបនោះ។

រដ្ឋគួរបង្កើត និងប្រើប្រាស់អភិក្រមផែនការរូបវន្ត ដោយគិតគូរផងដែរអំពីផលប្រយោជន៍នៃការនេសាទខ្នាតតូច និងតួនាទីនៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរចម្រុះ។

រដ្ឋគួរអនុម័តវិធានការគោលនយោបាយ ដើម្បីធានាសុខដុម្មនីយកម្មគោលនយោបាយនានាដែលមានឥទ្ធិពលមកលើសុខភាពនៃដែនទឹកសាប និងប្រព័ន្ធអេកូឡូស៊ីសមុទ្រ។

គោលនយោបាយជលផល គួរមានចក្ខុវិស័យរយៈពេលវែងសម្រាប់ការនេសាទខ្នាតតូចដែលមាននិរន្តរភាព។

រដ្ឋាភិបាល គួរមានជនបង្គោលដែលមានតែងតាំងច្បាស់លាស់នៅក្នុងស្ថាប័នមានសមត្ថកិច្ច និងទីភ្នាក់ងារនានា សម្រាប់សហគមន៍នេសាទខ្នាតតូច។

អ្នកពាក់ព័ន្ធក្នុងការនេសាទខ្នាតតូច គួរលើកកំពស់កិច្ចសហការក្នុងចំណោមអង្គការរបស់ខ្លួន។

រដ្ឋគួរលើកកំពស់រចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន ដែលរួមចំណែកក្នុងការគ្រប់គ្រងការនេសាទខ្នាតតូចឲ្យមានប្រសិទ្ធភាព។ កិច្ចសហប្រតិបត្តិការអន្តរជាតិ តំបន់ និងអនុតំបន់ គឺជាតម្រូវការចាំបាច់ដើម្បីធានាឲ្យការនេសាទខ្នាតតូចមាននិរន្តរភាព។



## ១១. ព័ត៌មាន ការស្រាវជ្រាវ និងការប្រាស្រ័យទាក់ទង

រដ្ឋគួរបង្កើតប្រព័ន្ធប្រមូលទិន្នន័យពាក់ព័ន្ធប្រកបដោយតម្លាភាព សម្រាប់ការធ្វើសេចក្តីសម្រេចលើការគ្រប់គ្រងការនេសាទខ្នាតតូចឲ្យមាននិរន្តរភាព។ ការធ្វើសេចក្តីសម្រេចដែលមានប្រសិទ្ធភាពទាមទារឲ្យមានទំនាក់ទំនង និងព័ត៌មាន។ រដ្ឋគួរប្រឹងប្រែងទប់ស្កាត់អំពើពុករលួយ បង្កើនតម្លាភាព និងតម្រូវឲ្យអ្នកធ្វើសេចក្តីសម្រេចចិត្តរ៉ាប់រងការទទួលខុសត្រូវ។

សហគមន៍នេសាទខ្នាតតូច គឺជាអ្នកកាន់កាប់ អ្នកផ្តល់ និងអ្នកទទួលចំណេះដឹង។ ព័ត៌មានពាក់ព័ន្ធ និងដែលចាំបាច់សម្រាប់ការនេសាទខ្នាតតូចប្រកបដោយការទទួលខុសត្រូវ និងការអភិវឌ្ឍដោយចីរភាព គួរតែមានសម្រាប់ការចែកចាយ។ គេគួរទទួលស្គាល់ និងចងក្រងជាឯកសារនូវចំណេះដឹង វប្បធម៌ ទម្លាប់អនុវត្ត និងបច្ចេកវិទ្យានានាសម្រាប់សហគមន៍នេសាទខ្នាតតូច។

រដ្ឋគួរផ្តល់ការគាំទ្រដល់សហគមន៍នេសាទខ្នាតតូច ជាពិសេស ជនជាតិដើម និងស្ត្រី ដែលពឹងផ្អែកលើការនេសាទសម្រាប់ការចិញ្ចឹមក្រពះ។ វេទិកា និងបណ្តាញការងារដែលមានស្រាប់ និងសមស្របនៅកម្រិតសហគមន៍ នៅថ្នាក់ជាតិ និងខ្ពស់ជាងនេះ ត្រូវតែបានយកមកប្រើប្រាស់ដើម្បីជម្រុញលំហូរ និងការផ្លាស់ប្តូរព័ត៌មាន។

រដ្ឋគួរមានមូលនិធិសម្រាប់ការស្រាវជ្រាវអំពីការនេសាទខ្នាតតូច និងលើកទឹកចិត្តឲ្យមានការប្រមូល និងការវិភាគទិន្នន័យ ដែលត្រូវធ្វើឡើងក្រោមកិច្ចសហការ និងតាមបែបចូលរួម។

រដ្ឋគួរជម្រុញការស្រាវជ្រាវលើប្រធានបទខុសៗគ្នា នៅក្នុងបរិបទនៃទំនាក់ទំនងយេនឌ័រ ដើម្បីផ្តល់ព័ត៌មានសម្រាប់យុទ្ធសាស្ត្រនានា ដែលជានាប្រយោជន៍ដោយសមធម៌សម្រាប់ទាំងបុរស និងស្ត្រីនៅក្នុងវិស័យនេសាទ។ នៅក្នុងការទទួលស្គាល់នូវតួនាទីរបស់ការនេសាទខ្នាតតូច និងដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃអាហារូបត្ថម្ភពីការបរិភោគត្រី រដ្ឋគួរជម្រុញការបរិភោគត្រីនៅក្នុងកម្មវិធីអប់រំអ្នកបរិភោគ។

## ១២. ការអភិវឌ្ឍសមត្ថភាព

សមត្ថភាពដើម្បីចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចគួរតែបានពង្រីក។

រដ្ឋគួរផ្តល់ការកសាងសមត្ថភាពសម្រាប់ការនេសាទខ្នាតតូច ដើម្បីទទួលផលពីឱកាសខាងទីផ្សារ។

ការអភិវឌ្ឍសមត្ថភាព គួរតែជាដំណើរការដែលជារចរន្តពីរទិស។ ចំណេះដឹងនិងជំនាញគួរតែបានអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព និងការចាត់ចែងសហគ្រប់គ្រងដែលមានជោគជ័យ។



## ១៣. ការគាំទ្រដល់ការអនុវត្ត និងការតាមដាន

ភាគីទាំងអស់ត្រូវបានទទួលការលើកទឹកចិត្តឲ្យអនុវត្តគោលការណ៍ណែនាំ SSF នេះ។

អ.ស.ប និងទីភ្នាក់ងារឯកទេសនានារបស់ខ្លួន គួរគាំទ្រដល់កិច្ចប្រឹងប្រែងស្ម័គ្រចិត្តរបស់រដ្ឋ ក្នុងការអនុវត្តគោលការណ៍ណែនាំទាំងនេះ។

រដ្ឋ និងភាគីដទៃទៀតទាំងអស់ ត្រូវធ្វើការជាមួយគ្នា ដើម្បីបង្កើតការយល់ដឹងអំពីគោលការណ៍ណែនាំនេះ និងផ្សព្វផ្សាយកំណែងាយៗ និងដែលបានប្រែសម្រួល។

សារៈសំខាន់នៃប្រព័ន្ធតាមដាន គួរតែមានការទទួលស្គាល់។ អ្នកតំណាងស្របច្បាប់នៃសហគមន៍នេសាទខ្នាតតូច គួរតែពាក់ព័ន្ធនៅក្នុងការរៀបចំ និងការចាត់ចែងប្រើប្រាស់យុទ្ធសាស្ត្រអនុវត្តសម្រាប់គោលការណ៍ណែនាំនេះ និងនៅក្នុងការតាមដានរបស់ខ្លួន។

អង្គការ FAO គួរជម្រុញ និងគាំទ្រដល់ការរៀបចំកម្មវិធីជំនួយជាសកល។





អត្ថបទទាំងមូលនៃគោលការណ៍ណែនាំស្ម័គ្រចិត្តសម្រាប់ធានាការនេសាទខ្នាតតូចដោយនិរន្តរភាព នៅក្នុងបរិបទនៃសន្តិសុខស្បៀង និងការលុបបំបាត់ភាពក្រីក្រ មាននៅក្នុង៖
http:/ /www.fao.org/fishery/topic/18240/en



International Collective in Support of Fishworkers (ICSF)
27 College Road, Chennai 600 006, India

ISBN 978 93 80802 46 6